# នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

## ព័ត៌មានពិស្តារនៃការដាក់ឯកសារ

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញា |
| ភាសាដើម | : | អង់គ្លេស |

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 22-Aug-2011, 15:16
CMS/CFO: Kauv Keoratanak

## ចំណាត់ថ្នាក់ឯកសារ

ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

---

## ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបរបស់ នួន ជា ពាក់ព័ន្ធនឹង ការខកខានជាលើកទីពីររបស់គាត់ ក្នុងការមិនគោរពតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់នូវបញ្ជីឯកសារ និងវត្ថុតាងដែលគាត់មានបំណងដាក់ នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង

---

| | | |
|---|---|---|
| **អ្នកដាក់ឯកសារ:** | **អ្នកទទួលឯកសារ:** | **ចម្លងជូន:** |
| សហព្រះរាជអាជ្ញា: | អង្គជំនុំជម្រះសាលាដំបូង: | ជនជាប់ចោទ: |
| លោកស្រី ជា លាង | ចៅក្រម និល ណុន, ប្រធាន | នួន ជា |
| លោក Andrew CAYLEY | ចៅក្រម Silvia CARTWRIGHT | អៀង សារី |
| | ចៅក្រម យ៉ា សុខន | អៀង ធីរិទ្ធ |
| | ចៅក្រមJean-Marc LAVERGNE | ខៀវ សំផន |
| | ចៅក្រម ធូ មណី | |
| | សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី: | មេធាវីការពារក្តីជនជាប់ចោទ: |
| | | លោក សុន អរុណ |
| | | លោក Michiel PESTMAN |

| | |
|---|---|
| ពេជ អង្គ | លោក Victor Koppe |
| Elisabeth SIMONNEAU FORT | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |

# I. សេចក្តីផ្តើម

១- សហព្រះរាជអាជ្ញាដាក់ការឆ្លើយតបនេះទៅនឹងចម្លើយតបរបស់មេធាវីការពារក្តី នួន ជា ("មេធាវីការពារក្តី") ពាក់ព័ន្ធនឹងការខកខានជាលើកទីពីររបស់ នួន ជា ក្នុងការមិនគោរពតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់នូវបញ្ជីឯកសារ និងវត្ថុតាងដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជំម្រះសាលាដំបូង ("ចម្លើយតប")[1]។ មេធាវីការពារក្តីស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងបដិសេធចោលសំណើរបស់សហព្រះរាជអាជ្ញាឈរលើមូលដ្ឋានថា ទណ្ឌកម្មដូចដែលបានបានស្នើឡើងនោះ គឺជាការខុសច្បាប់នៅក្រោមច្បាប់កម្ពុជា ឬបើតាមរបៀបផ្សេងវិញ មេធាវីការពារក្តីស្នើឱ្យអង្គជំនុំជម្រះសាលាដំបូងគួរបញ្ជូនទៅក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា("ក្រុមប្រឹក្សាធម្មនុញ្ញ")[2] តាមរយៈតុលាការកំពូល ត្រូវរង់ចាំការសម្រេចរបស់ស្ថាប័ននេះមុនធ្វើការសម្រេចលើសំណើនេះ។ ជាការបន្ថែម មេធាវីការពារក្តីស្នើឱ្យមានសវនាការជាសាធារណៈមួយលើសំណើនេះ[3]។

២- មេធាវីការពារក្តីព្យាយាមជំទាស់តវ៉ាជាថ្មីម្តងទៀត អំពីនីត្យានុកូលភាពធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង។ នៅក្នុងឱកាសនេះដែរ មេធាវីការពារអះអាងថា វិធាន៨០(៣)(ខ) និង(ឃ) "យ៉ាងហោចណាស់នៅពេលពិចារណាពាក់ព័ន្ធនឹងដំណោះស្រាយដែលបានស្វែងរក" ចំពោះការរំលោភនេះ នឹងជាការរំលោភលើកិច្ចការពារដែលបានផ្តល់ដោយមាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (CCPC)[4] និងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា[5]។ មេធាវីការពារក្តីចាត់ប្រភេទសំណើនេះ ពាក់ព័ន្ធនឹង "ធម្មនុញ្ញភាពនៃវិធាន៨០(៣)(ខ) និង(ឃ) និងដីកាបង្គាប់ស្តីពីការរៀបចំសវនាការក្រោយៗទៀត"[6] ហើយការអនុម័តវិធានទាំងនេះ គឺជាការប្រគល់អំណាចដោយមិនស្របច្បាប់របស់អង្គនីតិបញ្ញត្តិនៃរដ្ឋសភា[7]

[1] E109/5/1 ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើ ទាក់ទងនឹងការខកខានជាលើកទីពីររបស់ នួន ជា ក្នុងការមិនគោរពតាមដីការបស់អង្គជំនុំជម្រះសាលាដំបូង បង្គាប់ឱ្យផ្តល់បញ្ជីឯកសារ និងវត្ថុតាងដែលពួកគេមានបំណងដាក់នៅចំពោះមុខអង្គជំនុំជំម្រះសាលាដំបូង, ១៥ សីហា ២០១១, ERN 00725817-29 ("ចម្លើយតប") ។

[2] ដូចមានចែងដោយ *ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅរបស់ក្រុមប្រឹក្សាធម្មនុញ្ញ, ព្រះ*រាជក្រមលេខ: CS.RKM0498.06, ៨ មេសា ១៩៩៨ ។

[3] E109/5/1 ចម្លើយតប, *កំណត់សំគាល់ខាងដើមលេខ ១* ត្រង់កថាខ័ណ្ឌទី១, ៣៤-៣៧ ។

[4] E109/5/1 ចម្លើយតប, *កំណត់សំគាល់ខាងដើមលេខ ១* ត្រង់កថាខ័ណ្ឌ២០ ។

[5] E109/5/1 ចម្លើយតប, *កំណត់សំគាល់ខាងដើមលេខ ១* ត្រង់កថាខ័ណ្ឌទី២១-២៦ ។

[6] E109/5/1 ចម្លើយតប, *កំណត់សំគាល់ខាងដើមលេខ ១* ត្រង់កថាខ័ណ្ឌទី២៨ ។

[7] E109/5/1 ចម្លើយតប, *កំណត់សំគាល់ខាងដើមលេខ ១* ត្រង់កថាខ័ណ្ឌទី២២-២៣ ។

ដោយស្វែងរកការចោទសួរអំពីធម្មនុញ្ញភាពនៃកិច្ចប្រជុំពេញអង្គរបស់ អ.វ.ត.ក[8]។ សូមសន្និដ្ឋានថា សារណារបស់មេធាវីការពារក្តីទាំងនេះ គឺជារឿងច្រំដែល និងខ្វះមូលដ្ឋានច្បាប់។

## II. ច្បាប់

៣- ច្បាប់ជាធរមានដែលពាក់ព័ន្ធ គឺរួមមានបញ្ញត្តិនានានៃកិច្ចព្រមព្រៀង ច្បាប់ អវតក និងវិធានផ្ទៃក្នុង ("វិធាន") និងច្បាប់ស្តីពីនីតិវិធីរបស់កម្ពុជា។

៤- កិច្ចព្រមព្រៀងបានចែង៖

<u>មាត្រា១២៖ នីតិវិធី</u>

*១. នីតិវិធីត្រូវឲ្យស្របជាមួយច្បាប់កម្ពុជា។ នៅពេលច្បាប់កម្ពុជាពុំអាចដោះស្រាយបាន លើបញ្ហាពិសេសណាមួយ ឬមានភាពមិនច្បាស់លាស់ទាក់ទងទៅនឹងការបកស្រាយ ឬការអនុវត្តបទប្បញ្ញត្តិណាដែលពាក់ព័ន្ធនៅក្នុងច្បាប់កម្ពុជា ឬក៏មានបញ្ហាទាក់ទងទៅនឹងភាពសមស្របគ្នារវាងបទប្បញ្ញត្តិបែបនេះទៅនឹងបទដ្ឋានអន្តរជាតិ គេអាចស្វែងរកការណែនាំនៅក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅក្នុងកំរិតអន្តរជាតិ។*

*២. អង្គជំនុំជម្រះវិសាមញ្ញត្រូវអនុវត្តយុត្តាធិការរបស់ខ្លួន សមស្របតាមបទដ្ឋានយុត្តិធម៌អន្តរជាតិភាពត្រឹមត្រូវ និងដំណើរការសមស្របនៃច្បាប់ ដូចដែលមានចែងនៅក្នុងមាត្រា១៤ និង១៥ នៃកតិកាសញ្ញាអន្តរជាតិ ឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយដែលកម្ពុជាជាហត្ថលេខីដែរ។ ក្នុងផលប្រយោជន៍ដើម្បីធានាឲ្យមានសវនាការជាសាធារណៈ ហើយដំណើរការត្រឹមត្រូវ និងទុកចិត្តបាន ត្រូវយល់ថា រដ្ឋតំណាងជាសមាជិកនៃអង្គការសហប្រជាជាតិ តំណាងរបស់លោកអគ្គលេខាធិការ បណ្តាញព័ត៌មាន និងតំណាងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ នឹងអាចចូលរួមស្តាប់ការជំនុំជម្រះក្តីបានគ្រប់ពេលវេលាទាំងអស់។ការលើកលែងមិនឲ្យចូលរួមស្តាប់ការជំនុំជម្រះក្តីនេះ តាមមាត្រា១៤នៃកតិកាសញ្ញានេះ អាចធ្វើទៅបានតែក្នុងករណីចាំបាច់បំផុត តាមយោបល់*

[8] E109/5/1 ចម្លើយតប, *កំណត់សំគាល់ខាងដើមលេខ ១* ត្រង់កថាខ័ណ្ឌទី៣២ ។

*របស់អង្គជំនុំជម្រះដែលពាក់ព័ន្ធ ហើយតែពេលណាដែលការផ្សព្វផ្សាយចេញទៅនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍យុត្តិធម៌។*

៥- ច្បាប់ អវតក បានចែងថា៖

<u>មាត្រា៣៣:</u>

*អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវប្រព្រឹត្តទៅឱ្យបានត្រឹមត្រូវ និងឆាប់រហ័ស ទៅតាមនីតិវិធីជាធរមាន ដោយមានការគោរពយ៉ាងពេញលេញនូវសិទ្ធិរបស់ជនត្រូវចោទនិងមានការការពារឱ្យបានត្រឹមត្រូវចំពោះជនរងគ្រោះ និងសាក្សី។ បើមានការចាំបាច់ ហើយនីតិវិធីជាធរមាននោះមានការខ្វះចន្លោះ គេអាចស្វែងរកការណែនាំនៅក្នុងបទដ្ឋាននីតិវិធីដែលបានបង្កើតឡើងនៅក្នុងកំរិតអន្តរជាតិ។*

*អង្គជំនុំជម្រះសាលាដំបូង ត្រូវអនុវត្តយុត្តាធិការរបស់ខ្លួនឱ្យស្របតាមបទដ្ឋានអន្តរជាតិស្តីពីយុត្តិធម៌ ភាពត្រឹមត្រូវ និងស្របតាមនីតិវិធីច្បាប់ ដូចដែលមានចែងនៅក្នុងមាត្រាទី១៤ និង១៥ នៃកាតិកាសញ្ញាអន្តរជាតិឆ្នាំ១៩៥៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ។*

*ជនសង្ស័យដែលត្រូវបានចោទប្រកាន់ ហើយត្រូវបានចាប់ខ្លួន ត្រូវបញ្ជូនខ្លួនមកសាលាដំបូងតាមនីតិវិធីជាធរមាន។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវក្នុងការធានាសន្តិសុខចំពោះការចូលខ្លួនដោយស្ម័គ្រចិត្ត និងក្នុងការចាត់វិធានការឱ្យចាប់ខ្លួនជនសង្ស័យដែលត្រូវបានចោទប្រកាន់តាមច្បាប់នេះ។ នគរបាលយុត្តិធម៌ត្រូវបានជួយដោយអង្គភាពអនុវត្តច្បាប់ផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ដោយរួមមានកងកម្លាំងប្រដាប់អាវុធ ដើម្បីធានាដល់ជនដែលត្រូវបានចោទប្រកាន់ត្រូវបាននាំខ្លួនមកក្នុងមន្ទីរឃុំឃាំងភ្លាមៗ។*

*លក្ខណ្ឌនៃការចាប់ខ្លួន និងឃុំខ្លួនត្រូវអនុវត្តតាមច្បាប់ជាធរមាន។*

*តុលាការត្រូវផ្តល់ការការពារដល់ជនរងគ្រោះ និងសាក្សី។ វិធានការការពារនេះមិនត្រូវកំរិតត្រឹមតែកិច្ចដំណើរការការជំនុំជម្រះជាសម្ងាត់ និងការការពារនូវអត្តសញ្ញាណរបស់ជនរងគ្រោះឡើយ។*

៦- វិធានផ្ទៃក្នុងបានចែងថា៖

<u>វិធាន៨០.៣ (ខ) និង (ឃ)</u>:

*៣. អង្គជំនុំជម្រះសាលាដំបូងអាចបង្គាប់ឲ្យភាគីទាំងឡាយដាក់ឯកសារតាមពេលកំណត់មុនសវនាការបឋម រួមទាំងឯកសារខាងក្រោម៖ [...]*

*ខ). បញ្ជីវត្ថុតាងដែលភាគីទាំងឡាយមានបំណងប្រគល់ឲ្យសម្រាប់រឿងក្តីនោះ ដោយពិពណ៌នាត្រួសៗអំពីលក្ខណៈ និងខ្លឹមសារនៃវត្ថុតាងទាំងនោះ។*

*ឃ). បញ្ជីឯកសារថ្មីដោយមានភ្ជាប់សេចក្តីសង្ខេបពីខ្លឹមសារនៃឯកសារទាំងនោះ ដែលភាគីមានបំណងដាក់ចំពោះមុខអង្គជំនុំជម្រះ និងបញ្ជីឯកសារដែលមានស្រាប់នៅក្នុងសំណុំរឿងដែលបានកំណត់អត្តសញ្ញាណសមស្រប។*

៧- ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (“CCPC”) បានចែងថា៖

<u>មាត្រា៣៣៤៖</u>

*រហូតទល់នឹងការបិទការពិភាក្សាដេញដោល ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ដែលខ្លួនយល់ឃើញថាមានប្រយោជន៍ ដើម្បីសំដែងឲ្យឃើញការពិត។*

*សេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរត្រូវចុះទិដ្ឋាការដោយប្រធានសវនាការ និងក្រឡាបញ្ជី ហើយត្រូវភ្ជាប់ទៅក្នុងសំណុំរឿង។*

## III. **អំណះអំណាង**

### ក. ធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង និងកិច្ចប្រជុំពេញអង្គ ត្រូវបានដោះស្រាយរួចរាល់ទាំងស្រុង មិនចាំបាច់មានការពិនិត្យល្អិតល្អន់ទៀតទេ

៨- អង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូង បានសម្រេចស្របគ្នាអំពីធម្មនុញ្ញភាពនៃវិធានផ្ទៃក្នុង និងកិច្ចប្រជុំពេញអង្គ នៅក្នុងសេចក្តីសម្រេចនានាដែលមានសំអាងហេតុលើសារណានានារបស់មេធាវីការពារក្តី[9]។ ដូចមេធាវីការពារក្តីបានធ្វើសេចក្តីសង្កេតដែរ[10] ក្រុមប្រឹក្សាធម្មនុញ្ញបានសម្រេចរួចហើយអំពីធម្មនុញ្ញភាពនៃច្បាប់ អ.វ.ត.ក ដោយយោផ្តល់លទ្ធភាពឲ្យក្របខ័ណ្ឌច្បាប់ក្នុងស្រុករបស់កម្ពុជា អាចផ្តល់នូវកិច្ចប្រតិបត្តិការដោយឯករាជ្យរបស់ អ.វ.ត.ក[11]។ មាត្រា១ នៃសេចក្តីសម្រេចដែលមានសំអាងហេតុមួយរបស់ក្រុមប្រឹក្សាធម្មនុញ្ញចែងថា ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា “គឺត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ(...)”[12]។ អាស្រ័យហេតុនេះ ចរិកលក្ខណៈស្របនឹងរដ្ឋធម្មនុញ្ញនៃវិធានផ្ទៃក្នុង និងកិច្ចប្រជុំពេញអង្គ ពេលនេះត្រូវបានដោះស្រាយរួចរាល់ហើយ ហើយក៏មិនតម្រូវឲ្យមានការពិនិត្យឡើងវិញតាមផ្លូវតុលាការជាបន្តទៀតនោះទេ។ អង្គជំនុំជម្រះសាលាដំបូងមិនគួរអនុវត្តឲ្យមានសាកល្បងបន្ថែមទៀតទេ ចំពោះសេចក្តីសន្និដ្ឋានបែបនេះ ក្នុងការសម្រេចលើសំណើនេះឡើយ។

## ខ. ការបញ្ជូនបញ្ហានេះ តាមរយៈអង្គជំនុំជម្រះតុលាការកំពូល ទៅក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តាមច្បាប់មិនអាចធ្វើបានឡើយ

៩- មេធាវីការពារក្តីសន្និដ្ឋានថា បើសិនជាអង្គជំនុំជម្រះសាលាដំបូងទំនងជាមិនទទួលយកសំណើរបស់សហព្រះរាជអាជ្ញា អង្គជំនុំជម្រះសាលាដំបូងគួរពន្យារសេចក្តីសម្រេចរបស់ខ្លួនសិន ដោយរង់ចាំការបញ្ជូនទៅ“តុលាការកំពូលកម្ពុជា “ធម្មតា””[13] និងទៅក្រុមប្រឹក្សាធម្មនុញ្ញ[14] នូវសំណួរ “យ៉ាងហោចណាស់” ចំនួនបី។ សំណួរទាំងនេះពាក់ព័ន្ធនឹងធម្មនុញ្ញភាពនៃ (១)ទណ្ឌកម្មសុំឲ្យច្រានចោលជាមុន; (២)

---

[9] D55/I/8 សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់ នួន ជា, ប្រឆាំងចំពោះដីកាបដិសេធពាក្យសុំមោឃភាព, ២៦ សីហា ២០០៨ (អង្គបុរេជំនុំជម្រះ), ERN 00219322-33 (សាលដីកាលើបណ្តឹងឧទ្ធរណ៍មោឃភាព”) ។ E51/14 សេចក្តីសម្រេចលើអញ្ញត្រកម្មរបស់ នួន ជា ពាក់ព័ន្ធនឹងការចោទប្រកាន់ពីចរិកលក្ខណៈផ្ទុយគ្នានៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ទៅនឹងច្បាប់រដ្ឋធម្មនុញ្ញ, ៨ សីហា ២០១១ (អង្គជំនុំជម្រះសាលាដំបូង), ), ERN 00707531-35 (“សេចក្តីសម្រេចលើអញ្ញត្រកម្មបឋម”) ។

[10] E109/5/1 ចម្លើយតប, *កំណត់សំគាល់ខាងដើមលេខ ១* ត្រង់កថាខ័ណ្ឌទី៣៣ ។

[11] សំណុំរឿងលេខ: ០៣៨/០០១/២០០១ (១៧ មករា ២០០១), សេចក្តីសម្រេច លេខ: ០៤០/០០២/២០០១, ១២ កុម្ភៈ ២០០១, ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា, មាត្រា១ ។

[12] *ក្នុងឯកសារដដែលដូចខាងលើ* ។

[13] E109/5/1 ចម្លើយតប, *កំណត់សំគាល់ខាងដើមលេខ ១* ត្រង់កថាខ័ណ្ឌទី៣៦ ។

[14] *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី២៧-៣៣ ។

ការអនុម័តវិធាន៨០(៣)(ខ) និង(ឃ) និង(៣) វិធាន៨០(៣)(ខ) និង(ឃ) និងដីកាបង្គាប់ឲ្យដាក់សម្ភារៈរៀបចំសវនាការលើកទីមួយ និងពីរ[15]។

១០- នៅក្នុងកិច្ចព្រមព្រៀង, ច្បាប់ អ.វ.ត.ក ឬវិធានផ្ទៃក្នុង ពុំមានបទប្បញ្ញត្តិណាដែលមានចែងអំពីការបញ្ជូនបញ្ហាដែលស្ថិតក្រោមការពិចារណាតាមផ្លូវតុលាការនៅ អ.វ.ត.ក ទៅតុលាការដែលស្ថិតនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ឬស្ថាប័នផ្សេង ដូចជាក្រុមប្រឹក្សាធម្មនុញ្ញទេ។ អ.វ.ត.ក ជាតុលាការ "បំពេញកិច្ចដោយខ្លួនឯងទាំងស្រុង"[16] ឯករាជ្យ[17], បណ្តោះអាសន្ន[18] អន្តរតួបនីយកម្មពិសេស [19] ដោយ "ឋិតក្នុងរចនាសម្ព័ន្ធតុលាការកម្ពុជាដែលមានស្រាប់"[20] ធ្វើប្រតិបត្តិការផ្អែកតាមច្បាប់នីតិវិធីពិសេសដែលធ្វើដោយខ្លួនឯងទាំងស្រុង[21]។ ដោយធ្វើការវាយតម្លៃលើទំនាក់ទំនងរវាង អ.វ.ត.ក និងតុលាការកម្ពុជាក្នុងស្រុកធម្មតា អង្គបុរេជំនុំជម្រះបានសម្រេចថា គ្មានភាគីណាមួយមាន "សិទ្ធិសុំឲ្យតុលាការនៅក្រៅរចនាសម្ព័ន្ធរបស់ខ្លួន ពិនិត្យឡើងវិញនូវសេចក្តីសម្រេចណាមួយរបស់ អ.វ.ត.ក ឡើយ ឬដូចគ្នានេះដែរ ក៏គ្មានអង្គជំនុំជម្រះណាមួយរបស់ខ្លួន មានសិទ្ធិពិនិត្យលើសេចក្តីសម្រេចណាមួយពីតុលាការខាងក្រៅ អ.វ.ត.ក ដែរ"[22]។ អង្គជំនុំជម្រះសាលាដំបូងបានរកឃើញស្រដៀងគ្នានេះនៅក្នុងករណីរឿងរបស់ *ឌុចៈ "ពុំមានខ្សែរយៈសិទ្ធិអំណាចរវាង អវតក និងតុលាការដទៃទៀត*

[15] *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខ័ណ្ឌទី៣២ ។

[16] C5/45 បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន *ឌុច,* ចុះថ្ងៃទី៣ ខែធ្នូ ឆ្នាំ២០០៧ ERN 00154284-302 កថាខណ្ឌ១៨ ( "បណ្តឹងឧទ្ធរណ៍ស្តីពីការឃុំខ្លួនបណ្តោះអាសន្ន ករណី ឌុច") ។

[17] C5/45 *ក្នុងឯកសារដដែលដូចខាងលើ* ត្រង់កថាខ័ណ្ឌទី១៩។

[18] មាត្រា៤៧, ច្បាប់ អ.វ.ត.ក "អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវរំលាយខ្លួនជាស្វ័យប្រវត្តិ ក្រោយពេលដែលការវិនិច្ឆ័យទោសក្នុងរឿងក្តីនេះបានចប់ជាស្ថាពរ"។

[19] C5/45 បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន *ឌុច, កំណត់សំគាល់ខាងដើមលេខ* ១៦ ត្រង់កថាខ័ណ្ឌទី១៩ ការលើកយោងដោយមានការអនុម័តយល់ព្រមនូវសេចក្តីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ។

[20] សេចក្តីរៀបរាប់ទីបួននៃបុព្វកថានៃកិច្ចព្រមព្រៀង ។

[21] D55/I/8 សាលដីកាលើបណ្តឹងឧទ្ធរណ៍មោឃភាព, *កំណត់សំគាល់ខាងដើមលេខ* ៩ ត្រង់កថាខ័ណ្ឌទី១៤ ។

[22] C5/45 បណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងការឃុំខ្លួនបណ្តោះអាសន្ន *ឌុច, កំណត់សំគាល់ខាងដើមលេខ* ១៦ ត្រង់កថាខ័ណ្ឌទី១៨ ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ថា ទាក់ទងនឹងការចោទប្រកាន់នៃការឃុំខ្លួនជនសង្ស័យណាម្នាក់ដោយខុសច្បាប់នៅក្នុងតុលាការជាតិណាមួយ មុនពេលបញ្ជូនមក អ.វ.ត.ក កត្តានេះអាចត្រូវបានពិចារណា និងយកចិត្តទុកដាក់ក្នុងដំណាក់កាលនៅពេលក្រោយៗ នៅក្នុងដំណើរការនីតិវិធីរបស់ អ.វ.ត.ក ។ សូមអានកថាខ័ណ្ឌទី២៥ ។

*នៅក្នុងប្រព័ន្ធតុលាការរបស់កម្ពុជាឡើយ"*[23]។ អាស្រ័យហេតុនេះ គឺគ្មានមូលដ្ឋានច្បាប់សម្រាប់ការបញ្ជូនដូចបានស្នើឡើងដោយមេធាវីការពារក្តីទេ កុំថាឡើយតាម "បទដ្ឋានពិនិត្យដែលមានលក្ខណៈទូលំទូលាយ"[24] ឬតាមបទដ្ឋានផ្សេងនោះ។

**គ. វិធាន៨០(៣)(ខ) និង(ឃ) ពេលអានរួមគ្នាជាមួយវិធាន៨៧(៤) គឺស៊ីសង្វាក់គ្នានឹងមាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា (CCPC) ហើយផ្តល់នូវច្បាប់ជាធរមានដ៏ជាក់លាក់បំផុត ស្តីពីការដាក់បញ្ជីឯកសារ និងវត្ថុតាង នៅមុនកិច្ចដំណើរការនីតិវិធីសវនាការ**

១១- មេធាវីការពារក្តីពឹងផ្អែកលើមាត្រា៣៣៤ ក្រមនីតិវិធីព្រហ្មទណ្ឌ CCPC ថាជា "បទប្បញ្ញត្តិសំខាន់បំផុត" ដែលត្រូវអនុវត្តចំពោះបញ្ហា "ការដាក់ឯកសារ និងវត្ថុតាងរហូតដល់ចុងបញ្ចប់" នៃកិច្ចដំណើរការនីតិវិធីនៅមុនពេលសវនាការ[25]។ ក្នុងការធ្វើអំណះអំណាងដូច្នេះ មេធាវីការពារក្តីស្នើថា ដោយសារ "បញ្ហាពិសេសនេះ" មានចែងយ៉ាងច្បាស់នៅក្នុងច្បាប់កម្ពុជា នៅក្នុងមាត្រា១២ នៃកិច្ចព្រមព្រៀង និងនៅក្នុងមាត្រា៣៣ថ្មី នៃច្បាប់ អ.វ.ត.ក គឺមិនអនុញ្ញាតឲ្យអង្គជំនុំជម្រះពិនិត្យមើលលើបទដ្ឋានអន្តរជាតិ ក្រៅពីសិទ្ធិរបស់ជនជាប់ចោទ ក្នុងការដាក់បញ្ចូលនូវភ័ស្តុតាងដែលពាក់ព័ន្ធនៅក្នុងពេលសវនាការឡើយ[26]។

១២- លំដាប់លំដោយនៃអំណះអំណាងមិនបានទទួលស្គាល់នូវភាពពាក់ព័ន្ធនៃច្បាប់ធរមានជាក់លាក់ (*ការបកស្រាយច្បាប់*) ដែលទាក់ទងទៅនឹងសិទ្ធិរបស់អង្គជំនុំជម្រះសាលាដំបូង ក្នុងការចាត់ចែងដោយមានប្រសិទ្ធភាពលើរឿងក្តីព្រហ្មទណ្ឌនានាដែលមានទំហំធំ និងមានលក្ខណៈស្មុគស្មាញ ដើម្បីធានាថា ការជំនុំជម្រះក្តីបានប្រកបដោយភាពត្រឹមត្រូវផង និងឆាប់រហ័សផង។ បទដ្ឋានមួយចំនួននៃបទដ្ឋានទាំងនេះ ត្រូវបានទទួលស្គាល់ជាទូទៅនៅក្នុង វិធាន៨០ នៃវិធានផ្ទៃក្នុង ដោយឡែកនៅក្នុងវិធាន៨០.៣ (ខ) និង(ឃ) ទាក់ទងនឹងការគ្រប់គ្រងឯកសារនៅក្នុងពេលសវនាការ[27]។ លំដាប់លំ

---

[23] **E39/5** សេចក្តីសម្រេចលើសំណើសុំដោះលែង ចុះថ្ងៃទី១៥ កក្កដា ២០០៩ ERN ០០៣៣៨៨៣២ ដល់៤៦ ត្រង់កថាខ័ណ្ឌទី១២ ដែលលើកសំអាងលើមាត្រា៣៦ថ្មី នៃច្បាប់ អវតក។

[24] **E109/5/1** ចម្លើយតប, *កំណត់សំគាល់ខាងដើមលេខ ១* ត្រង់កថាខ័ណ្ឌទី៣៣ ។

[25] **E109/5/1** ចម្លើយតប, *ដូចគ្នានឹងខាងលើ* ត្រង់កថាខ័ណ្ឌទី៩, ១២ ។ សូមអានជាទូទៅ កថាខ័ណ្ឌទី១០-១៧ ។

[26] **E109/5/1** ចម្លើយតប, *ក្នុងឯកសារដដែលដូចខាងលើ,* ត្រង់កថាខណ្ឌ ១២-១៣ ។

[27] **E109/5/1** *កំណត់សំគាល់លេខ ១ ខាងលើ,* ត្រង់ផ្នែក IV ក ។

ដោយនៃទឡ្ហីករណ៍ដែលបញ្ជូនឡើងដោយមេធាវីការពារក្តី ក៏មានភាពស៊ីសង្វាក់គ្នាជាមួយនឹងគោលការណ៍នានា ដែលបានប្រកាន់យកដោយអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងដែរ។

១៣- ទាំងអង្គបុរេជំនុំជម្រះ និងទាំងអង្គជំនុំជម្រះសាលាដំបូង បានបញ្ជាក់ថា វិធានផ្ទៃក្នុង បង្កើតបានជា"របបដែលបំពេញកិច្ចដោយខ្លួនឯងទាំងស្រុងនៃច្បាប់នីតិវិធី" ដែលទាក់ទងទៅនឹង "កាលៈទេសៈពិសេសតែមួយគ្មានមានពីររបស់ អវតក ដែលត្រូវបានបង្កើតឡើង និងត្រូវបានព្រមព្រៀងគ្នានៅក្នុងសម័យប្រជុំពេញអង្គរបស់ អវតក ហើយថា វិធានទាំងនេះ" និងថា "វិធានទាំងនេះគឺមិនមែនមានអត្ថិភាពសម្រាប់ប្រឆាំងនឹងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជានោះទេ"[28]។ អង្គជំនុំជម្រះទាំងពីរនេះបានសម្រេចបន្ថែមទៀតថាវិធានទាំងនេះគឺជា "លិខិតុបករណ៍ដ៏ចំបងដែលគួរតែបានលើកយោងដើម្បីធ្វើការកំណត់សម្រេចអំពីនីតិវិធីផ្សេងៗនៅចំពោះមុខ អវតក" នៅក្នុងករណីបើសិនជា "មានភាពមិនស្របគ្នា" រវាងវិធានផ្ទៃក្នុង និងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា[29]។

១៤- ក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា, កិច្ចព្រមព្រៀង, និងច្បាប់ អវតក អនុញ្ញាតឲ្យ អវតក អាចបង្កើតនូវវិធានពិសេស សម្រាប់ដំណើរការនីតិវិធីរបស់ខ្លួនបាន។ មាត្រា១ នៃក្រមនីតិវិធីកម្ពុជាចែងថា ក្រមនីតិវិធីព្រហ្មទណ្ឌមានគោលបំណងកំណត់អំពីវិធានទាំងឡាយ ដែលត្រូវគោរពប្រតិបត្តិតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ។ "[]បទប្បញ្ញត្តិនៃក្រមនេះត្រូវយកទៅអនុវត្តចំពោះរឿងព្រហ្មទណ្ឌនានា ប្រសិនបើពុំមានវិធានដោយឡែកចែងដោយច្បាប់ទេនោះ"។ កិច្ចព្រមព្រៀង និងច្បាប់ អវតក ក៏បានគ្រោងទុកផងដែរអំពីការចាប់ផ្តើមចេញដំណើរពីនីតិវិធីរបស់កម្ពុជាជាធរមាន នៅក្នុងករណីដែលមាន "បញ្ហាពិសេសដោយឡែកណាមួយ"មិនត្រូវបានលើកឡើង ឬនៅពេលដែលមានភាពស្រពិចស្រពិលមិនច្បាស់លាស់ ក្នុងការបកស្រាយ ឬមានបញ្ហាស្តីពីភាពមិនស៊ីសង្វាក់គ្នាជាមួយនឹងបទដ្ឋានអន្តរជាតិ។ មេធាវីការពារក្តីបានទទួលស្គាល់ទាំងស្រុងអំពីរឿងនេះ នៅក្នុងចម្លើយតបរបស់ខ្លួន[30]។

[28] ឯកសារលេខ D55/I/8, សាលដីកាស្តីពីការចាត់ទុកជាមោឃៈនូវបណ្តឹងឧទ្ធរណ៍, ដូចនៅក្នុងកំណត់សំគាល់លេខ៩ខាងលើ ត្រង់កថាខណ្ឌទី១៤។ ឯកសារលេខ E51/14, ដីកាសំរេចលើអញ្ញត្រកម្មបឋម, ដូចនៅក្នុងកំណត់សំគាល់លេខ៩ *ខាងលើ* ត្រង់កថាខណ្ឌទី៧។

[29] ឯកសារលេខ D55/I/8, *ដូចគ្នានឹងខាងលើ*។ ឯកសារលេខ E51/14, *ដូចគ្នានឹងខាងលើ*។

[30] ឯកសារលេខ E109/5/1, ចម្លើយតប, ដូចនៅក្នុងកំណត់សំគាល់លេខ១ ខាងលើ ត្រង់កថាខណ្ឌទី១១។

១៥- បន្ទាប់ពីនេះមក មេធាវីការពារក្តីបានកំណត់ចរិតលក្ខណៈនៃបញ្ហានេះដោយមិនត្រឹមត្រូវ ដោយថាជាបញ្ហាមួយពាក់ព័ន្ធទៅនឹង "សិទ្ធិក្នុងការដាក់ឯកសារ និងភស្តុតាងរហូតទល់នឹងពេលចប់សវនាការជំនុំជម្រះក្តី"ទៅវិញ[31] ដើម្បីបង្ហាញថា វិធាន៨០.៣(ខ) និង(ឃ) រួមជាមួយនឹងដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការលើកទី១ និងលើកទី២ គឺជាការបំពានទៅលើការការពារដែលបានសន្មតនៅក្នុងមាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ គ្មានភាពមិនស៊ីសង្វាក់គ្នាបែបនេះទេ។ វិធានដែលពាក់ព័ន្ធ និងដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការដែលស្ថិតនៅក្រោមវិធាននោះ គឺទាក់ទងទៅនឹងការគ្រប់គ្រងដោយមានប្រសិទ្ធភាពរបស់តុលាការ នូវឯកសារភ័ស្តុតាង និងភស្តុតាងដទៃទៀតនៅក្នុងដំណើរការនីតិវិធីនៃរឿងក្តីព្រហ្មទណ្ឌ ដែលមានលក្ខណៈស្មុគស្មាញ និងពិសេសដែលមានតែមួយគត់ ដែលអនុវត្តជាចំបងតាមគោលការណ៍អន្តរជាតិនានា ហើយដែលខុសគ្នា"យ៉ាងខ្លាំងគួរសម ពីដំណើរការប្រព្រឹត្តិទៅធម្មតារបស់តុលាការព្រហ្មទណ្ឌនានារបស់កម្ពុជា ក្នុងការអនុញ្ញាតិឲ្យមានប្រព័ន្ធដែលមានជំនាញឯកទេសមួយ"[32]។ សហព្រះរាជអាជ្ញាសូមស្នើយោងទៅលើបទដ្ឋានអន្តជាតិនានាដែលត្រូវបានបង្កើតឡើង ស្តីពីការគ្រប់គ្រងភ័ស្តុតាងនៅចំពោះមុខតុលាការឧក្រិដ្ឋកម្មអន្តរជាតិ និងតុលាការឧក្រិដ្ឋកម្មអន្តរជាតូបនីយកម្មនានា ដោយវិធាន៨០.៣(ឃ) នៃវិធានផ្ទៃក្នុង និងដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការ មានលក្ខណៈស្របគ្នាទាំងស្រុងទៅនឹងបទដ្ឋានទាំងនេះ[33]។

១៦- មាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានដំកល់នូវគោលការណ៍ទូទៅមួយ។ មាត្រានេះមិនបានពោលអះអាងអំពីភាពជាក់លាក់សម្រាប់ដោះស្រាយចំពោះករណីរឿងដែលមានលក្ខណៈស្មុគស្មាញដែលពាក់ព័ន្ធនឹងឯកសារចំនួនរាប់ពាន់ដែលសំខាន់ជាសារវន្ត ដើម្បីឲ្យការគ្រប់គ្រងកិច្ចការរដ្ឋបាលរបស់តុលាការបានត្រឹមត្រូវ ភាគីទាំងឡាយតែងតែមានការខិតខំប្រឹងប្រែងដោយសុចចិត្តដើម្បីកំណត់អត្តសញ្ញាណរបស់សាក្សីនានា និងឯកសារផ្សេងៗដែលបានស្នើឡើង ដែលខ្លួនមានបំណងផ្តល់ជូន។ មាត្រានេះក៏មិនអាចរឹតត្បឹតចំពោះសិទ្ធិអំណាចដែលមានជាប់មកជាមួយស្រាប់របស់អង្គ

---

[31] ឯកសារលេខ E109/5/1, ចម្លើយតប, ដូចនៅក្នុងកំណត់សំគាល់លេខ១ ខាងលើ ត្រង់កថាខណ្ឌទី៨-៩។

[32] ឯកសារលេខ D55/I/8, សាលដីកាស្តីពីការចាត់ទុកជាមោឃៈនូវបណ្តឹងឧទ្ធរណ៍, ដូចនៅក្នុងកំណត់សំគាល់លេខ៩ខាងលើ ត្រង់កថាខណ្ឌទី១៥។ ឯកសារលេខ E51/14, ដីកាសំរេចលើអញ្ញត្រកម្មបឋម, ដូចនៅក្នុងកំណត់សំគាល់លេខ៩ *ខាងលើ* ត្រង់កថាខណ្ឌទី៧។

[33] ឯកសារលេខ E109/5, ចម្លើយតប, ដូចនៅក្នុងកំណត់សំគាល់លេខ១ ខាងលើ ត្រង់កថាខណ្ឌទី១៦,១៩-២០។

ជំនុំជម្រះសាលាដំបូង មិនឲ្យចេញដីកាបង្គាប់ដែលចាំបាច់ៗ ដើម្បីធានាឲ្យប្រាកដថា ការជំនុំជម្រះក្តី ត្រូវបានធ្វើឡើងដោយភាពត្រឹមត្រូវ និងដោយឆាប់រហ័សបានដែរ។

១៧- ទាំងវិធានផ្ទៃក្នុងក្តី ឬទាំងដីកាបង្គាប់ឲ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការក្តី គឺមិនបានច្រានចោលជាមុន មិនឲ្យមេធាវីដាក់ឯកសារនានា និងភ័ស្តុតាងដទៃទៀត នៅក្នុងដំណាក់កាលជាបន្ទាប់ទៀតនៃដំណើរការនីតិវិធី នៅក្នុងសារណាដែលមានផ្តល់ហេតុផលក្នុងបុព្វហេតុដែលល្អនោះឡើយ (ឧទាហរណ៍ដូចជា នៅក្នុងករណីដែលមានការរកឃើញនូវភ័ស្តុតាងថ្មីៗ)។ វិធាន៨៧(៤) បានតម្កល់យ៉ាងជាក់លាក់នូវសិទ្ធិនេះ ហើយដែលស្របគ្នាជាមួយនឹងមាត្រា៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា។ ខ្លឹមសាររួមជាមួយគ្នានៃវិធាន៨៧(៤), វិធាន៨០.៣(ខ) និង(ឃ) នៃវិធានផ្ទៃក្នុង ដែលចែងអំពីច្បាប់ជាធរមានដែលមានលក្ខណៈជាក់លាក់ជាង (*ការបកស្រាយច្បាប់ lex specialis*) ដែលទាក់ទងនឹងការដាក់បញ្ជីឯកសារ និងវត្ថុតាងនានា នៅមុនដំណើរការនៃការជំនុំជម្រះក្តី។

## ឃ. អង្គជំនុំជម្រះសាលាដំបូងអាចដាក់ទណ្ឌកម្មស្របតាមច្បាប់ចំពោះការរំលោភបំពានច្រំដែលៗលើវិធាន៨០.៣(ខ) និង៨០.៣(ឃ) នៃវិធានផ្ទៃក្នុង

១៨- ក្នុងករណីដែលភាគីនានាខកខានមិនបានអនុវត្តតាមវិធាននីតិវិធីពិសេសនានា ដែលយកមកអនុវត្តសម្រាប់ដំណើរការនីតិវិធីនៅចំពោះមុខ អវតក ដែលរួមទាំងវិធាន៨០ផងនោះ នៅក្នុងវិធានផ្ទៃក្នុងមានបញ្ញត្តិនានាដែលចែងពីការដាក់ទណ្ឌកម្មផ្សេងៗ ដែលអង្គជំនុំជម្រះត្រូវធ្វើការពិចារណា[34]។ សហព្រះរាជអាជ្ញាសូមស្នើដោយគោរពដល់អង្គជំនុំជម្រះសាលាដំបូងសូមយោងទៅលើឯកសារដែលបានដាក់ជូនកាលពីលើកដំបូងៗ ដែលក្នុងនោះមានសំណើសុំឲ្យដាក់ទណ្ឌកម្មផ្សេងៗ ដែលរួមទាំងទណ្ឌកម្មហាមឃាត់ជាមុនផង ទាក់ទងនឹងការបង្ហាញឯកសារ និងភ័ស្តុតាងនានានៅក្នុងពេលសវនាការ និងការដាក់ទណ្ឌកម្មលើបុគ្គលដែលទាក់ទងនឹងសីលធម៌របស់មេធាវីដែលចូលបង្ហាញខ្លួននៅចំពោះមុខ អវតក[35]។

---

[34] វិធាន៣៥.១(ខ)។

[35] ឯកសារលេខ E109/5, សំណើសុំ, ដូចនៅក្នុងកំណត់សំគាល់លេខ១ ខាងលើ ត្រង់កថាខណ្ឌទី១១-២១, ៣១។

## IV. ឧបាស្រ័យដែលបានស្នើសុំ

១៩- អាស្រ័យដោយមូលហេតុដូចដែលបានលើកឡើងខាងលើនេះ និងដូចដែលមាននៅក្នុងសំណើសុំកាលពីដំបូង សហព្រះរាជអាជ្ញាសូមស្នើដោយគោរពសូមឱ្យអង្គជំនុំជម្រះសាលាដំបូង៖

(ក) ហាមឃាត់ជាមុនកុំឱ្យមេធាវីការពារក្តីធ្វើការបង្ហាញនៅក្នុងពេលសវនាការនូវឯកសារ និងភស្តុតាងផ្សេងទៀតដែលមិនបានកំណត់អត្តសញ្ញាណអនុលោមទៅតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការលើកទី១ និងលើកទី២ ឬផ្ទុយទៅវិញ

(ខ) សូមណែនាំដល់មេធាវីការពារក្តី ឱ្យអនុវត្តតាមដីកាបង្គាប់ឱ្យដាក់សម្ភារៈសម្រាប់ត្រៀមរៀបចំសវនាការលើកទី១ និងលើកទី២ ក្នុងរយៈពេលពីរសប្តាហ៍យ៉ាងយូរ ការខកខានមិនបានអនុវត្តតាម នឹងត្រូវដាក់ឱ្យទទួលរងនូវទណ្ឌកម្មហាមឃាត់ជាមុនផង និង

(គ) សូមសម្រេចលើសំណើសុំ ដោយផ្អែកលើមូលដ្ឋាននៃការដាក់ឯកសារជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះបានហើយ ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី២២ ខែសីហា ឆ្នាំ២០១១ | **លោកស្រី ជា លាង**<br>សហព្រះរាជអាជ្ញា | ភ្នំពេញ | [signature] |
| | **លោក** William SMITH<br>សហព្រះរាជអាជ្ញារង | | [signature] |

ការឆ្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងចម្លើយតបរបស់ នួន ជា ពាក់ព័ន្ធនឹងការខកខានជាលើកទីពីររបស់គាត់ ក្នុងការមិនគោរពតាមដីកាបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូង ដើម្បីផ្តល់នូវបញ្ជីឯកសារ និងវត្ថុតាងដែលគាត់មានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង